**Program:** ឃាតកម្មមុនចូលគេង

**Topic:** Paul Kenneth BERNARDO
ឃាតកសង្ហាររោគចិត្តដែលសម្លាប់ និងបំពានផ្លូវភេទ
**Categories:** Crime Investigation

**Check: Pending**

**Content by:** Prey Reung

---

សូមស្វាគមន៏មកកាន់CamID Podcast!

អ្នកទាំងអស់គ្នា ប្រាកដជាធ្លាប់លឺមកហើយ អំពើឃាតកសម្លាប់មនុស្សទៅតាមប្រភេទនីមួយៗ ថ្ងៃនេះ ព្រៃរឿងនឹងនាំអ្នកទាំងអស់គ្នា អោយមកស្គាល់ឃាតកជនជាតិកាណាដាវ័យក្មេងម្នាក់ ដែលត្រូវបានគេស្គាល់ថា ជាឃាតកព្រៃផ្សៃដែលបំពាន និងធ្វើឃាត។

ក្នុងនោះ មានជនរងគ្រោះដែលត្រូវគេបំពានយ៉ាងហោចណាស់១៦នាក់ឡើងទៅ និងជនរងគ្រោះ ដែលត្រូវគេសម្លាប់ គឺចាប់ពី៣នាក់ឡើងទៅ។

អ្វីដែលនឹកស្មានមិនដល់នោះ ប្រពន្ធរបស់គេ ក៏មានវត្តនៅក្នុងការសម្លាប់ជនរងគ្រោះទាំងអស់នោះដែរ និងថែមទាំងថតជាវីដេអូ ពីសកម្មភាព ដែលពីរនាក់ប្ដីប្រពន្ធរបស់គេ ចាប់បំពានប្អូនស្រីរបស់ខ្លួនទៀតផង។

ម្យ៉ាងទៀត ឃាតកដែលជាប្រពន្ធ បានឈរមើលប្ដីរបស់គេ បំពានផ្លូវភេទប្អូនស្រីរបស់ខ្លួន ទាំងសេចក្ដីសាទរទៀតផង ហើយហួសចិត្តជាងនេះ គេថែមទាំងរៀបរាប់ថា ការធ្វើបែបនេះ គឺជាការជូនកាដូព្រហ្មចារីប្អូនស្រីរបស់ខ្លួន ទៅអោយប្ដីនាងនៅថ្ងៃបុណ្យណូអែល។

ស្តាប់ទៅវាជារឿងមួយ ដែលគ្មានអ្នកណាអាចធ្វើទៅរួចនោះទេ តែប្ដីប្រពន្ធមួយគូនេះ អាចធ្វើទៅរួច ដោយហានថតជាវីដេអូទៀតផង។

តើពួកគេទាំងពីរមានប្រវត្តបែបណា? ហេតុអ្វីបានជាប្រពន្ធ ដែលជាឃាតក ហ៊ានធ្វើរឿងបែបនេះ ដោយភ្លេចថាខ្លួនជាអ្នកណា?

រឿងនេះ នឹងនាំអ្នកទាំងអស់គ្នា អោយមកស្គាល់បុរសម្នាក់ ដែលមានឈ្មោះថា Paul Kenneth Bernardo។

Paul កើតនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៦៤ នៅក្នុងស្រុក Scarborough រដ្ឋ Ontario នៃប្រទេសកាណាដា ដែលមានឪពុកឈ្មោះKenneth និងម្ដាយឈ្មោះMarilyn Bernardo។

Paul  មានបងប្អូន៣នាក់ ក្នុងចំណោមនោះ គេគឺជាកូនពៅ។ គ្រួសាររបស់គេ មិនសូវមានសុភមង្គលប៉ុន្មាននោះទេ ព្រោះឪពុករបស់គេតែងតែប្រព្រឹត្តអំពើស្មោគគ្រោគ ដោយតែងតែលួចមើលសមាជិកគ្រួសាររបស់ខ្លួន ងូតទឹក និងផ្លាស់សម្លៀកបំពាក់ជាដើម។ មិនតែប៉ុណ្ណោះ ថែមទាំងធ្វើបាបបងស្រីរបស់Paul ជារឿយៗ ទៀតផង។

ចំណែកឯម្តាយរបស់គេ គឺជាមនុស្សម្នាក់ ដែលមានជម្ងឺបាក់ទឹកចិត្ត និងតែងតែហាមឃាត់ សមាជិកគ្រួសាររបស់ខ្លួន មិនអោយទៅលេងសាច់ញាតិផ្សេងបានឡើយ។ ទោះបីជាយ៉ាងណា ជីវិតរបស់Paul នៅតែមានភាពរីករាយដដែរ។

ឆ្នាំ១៩៨១ នៅពេលដែលPaul មានអាយុ១៧ឆ្នាំ ។ Paul មានបញ្ហាជាមួយម្តាយរបស់គេ ដោយ គេបានឈ្លោះជាមួយម្តាយរបស់គេ អំពីរឿង ដែល Kenneth Bernardo មិនមែនជាឪពុកបង្កើតរបស់គេ នៅពេលដែលPaulដឹងថា គេគឺជាកូន ដែលកើតមក រវាងម្តាយរបស់គេនិងបុរសម្នាក់ទៀត ដែលជាប្រុសកំណាញ់របស់ម្តាយគេ។

ហើយ Paul បានហៅម្តាយគេថាជា មនុស្សកង្វក់ និងស្រីពេស្យាចារ។ ចំណែកឯម្តាយរបស់គេបានហៅPaulវិញថា កូនឥតខាន់ស្លា។

ជម្លោះរវាងគេ និងម្តាយគេ មិនទាន់បានផ្សះផ្សាផងស្រាប់តែ ក្រោយមក គេក៏ត្រូវ Nadine Brammer ដែលជាសង្សារទីមួយរបស់គេ បានបោះបង់គេចោល រួចទៅយកអ្នកថ្មី ដែលជាមិត្តភក្តិរបស់ Paul ព្រោះថា Nadine មិនអាចទ្រាំជាមួយ អត្តចរិករបស់គេបានទៀតនោះទេ។

ដោយសារកំហឹង Paul ក៏បានដុតបំផ្លាញ វត្ថុអនុស្សាវរីយ៍ទាំងប៉ុន្មាន ដែលគេមានជាមួយនឹង Nadineចោលទាំងអស់ នៅពេលនោះ។

លុះក្រោយមក Paul ក៏បានបញ្ចប់ការសិក្សា ពីមហាវិទ្យាល័យ Sir Wilfrid Laurier រួចហើយ Paul ក៏ទៅធ្វើការ នៅក្នុងក្រុមហ៊ុនអាមេរិកមួយ ដែលមានឈ្មោះថា  Amway ដែលវប្បធម៌នៃការលក់នៅទីនោះ មានឥទ្ធិពលទៅលើPaul យ៉ាងខ្លាំង។

នៅពេលដែលគេចាប់ផ្តើមចូលរៀននៅសាកលវិទ្យាល័យ Toronto នៃក្រុង Scarborough Paul ក៏បែកគំនិត ដោយគេបានបង្កើតទីផ្សារផ្លូវភេទងងឹតមួយ ដែលមានឈ្មោះថា“ កសិដ្ឋានព្រហ្មចារី” ដែលនៅទីនោះ គេនឹងយកក្មេងស្រីព្រហ្មចារី មកចញ្ចឹមដើម្បីទុកចាប់បំពានផ្លូវភេទនៅថ្ងៃមុខ។

គ្រានោះ គេតែងតែណាត់ជួបនារីជាច្រើននាក់ ក្នុងពេលតែមួយថែមទៀតផង។ និយាយជារួម គ្រប់ការណាត់ជួបទាំងអស់ គេតែងតែធ្វើបាប និងគំរាមសម្លាប់មិត្តស្រីរបស់គេ ប្រសិនបើពួកនាងនិយាយរឿងដែលPaul ធ្វើបាបពួកនាងទៅកាន់អ្នកដទៃ។

នៅឆ្នាំ១៩៨៦ ស្ត្រីពីរនាក់ ត្រូវបានទទួលសិទ្ធផ្តឹងទៅPaul ពីបទខលទៅពួកគេ និយាយពាក្យមិនសមរម្យដាក់នាង ក៏ប៉ុន្តែពួកនាងមិនផ្តឹងនោះទេ ហើយការធ្វើបែបនេះ បានបណ្តោយអោយPaul បានចិត្ត បំពានទៅលើនារីជាច្រើនទៀត។

លុះមកដល់ខែតុលា ឆ្នាំ១៩៨៧ Paul បានជួបនឹង Karla Homolka។ ដោយពួកគេ មានសម្រស់ និងអត្តចរិកដូចគ្នា។ ទីបំផុត ពួកគេក៏ស្រលាញ់គ្នា និងក្លាយជាប្តីប្រពន្ធនឹងគ្នា តាំងពីពេលហ្នឹងមក។ គួរបញ្ជាក់ផងដែរថា ប្រពន្ធរបស់គេធ្វើការជាពេទ្យសត្វ។

ចាប់តាំងពីពេលនោះមក Paul បានប្រព្រឹត្តអំពើរំលោភបំពានផ្លូវភេទ ជាច្រើនជុំវិញទីក្រុង Scarborough ក៏ប៉ុន្តែម្តងនេះ Paul មិនដូចមុនទៀតទេ ពោលគឺគេកាន់តែសាហាវឃោរឃៅ ជាងពេលមុនៗទៀតផង ដោយ គេតែងតែចាំវាយប្រហារទៅលើស្ត្រីណា ដែលចុះពីឡានក្រុងនៅពេលល្ងាច និងពេលយប់។

សរុបមក ចាប់ពីឆ្នាំ១៩៨៧ ដល់ឆ្នាំ១៩៩០ គឺចំនួនជនរងគ្រោះដែលPaulបានបំពានផ្លូវភេទបានសម្រេច គឺលើសពី១៣នាក់ទៅទៀត។

ជនរងគ្រោះទាំងអស់ សុទ្ធតែរស់នៅតំបន់Scarborough។ នេះគឺជាចំនួនមួយ ដែលជនរងគ្រោះជាច្រើននាក់ ត្រូវបានPaulតែម្នាក់ បំពាននិងមិនធ្លាប់មានពីមុនមកនៅក្នុងប្រទេសកាណាដាទេ

ហេតុដល់ករណីនេះ បានធ្វើអោយគេ មានរហ័សជាភាសាអង់គ្លេសថា The Scarborough Rapist និងរហ័សនាមមួយទៀតគឺ The Schoolgirl Killer ព្រោះជនរងគ្រោះភាគច្រើន គឺជាសិស្សសាលាក្មេងៗ ដែលមានអាយុចាប់ពី១៥ ទៅ២២ឆ្នាំ។

មកដល់ចំណុចនេះ អ្នកទាំងគ្នាប្រាកដជាឆ្ងល់ហើយថា ហេតុអ្វីបានជាមិនមានការចាប់ខ្លួន ទៅលើរូបគេយ៉ាងដូច្នោះ?

តាមការពិតទៅ ចាប់ពីខែឧសភា ដល់ខែកញ្ញាឆ្នាំ ១៩៩០ ប៉ូលីសបានបញ្ជូនជនសង្ស័យជាង ១៣០ នាក់ យកទៅធ្វើតេស្ត DNA រួចប៉ូលីស ទទួលបានតម្រុយចំនួនពីរ ពីមនុស្សដែលពួកគេកំពុងស្វែងរក នោះគឺPaulនោះឯង។

ទីមួយ គឺនៅក្នុងខែមិថុនា Paulត្រូវបានគេប្តឹងដោយបុគ្គលិកធនាគារម្នាក់ ហើយនិងលើកទីពីរ គេត្រូវបានប្តឹងដោយនារីម្នាក់ឈ្មោះថា Tina Smirnis។គួរបញ្ជាក់ផងដែរថា Tina ត្រូវជាភរិយាជាមួយបងប្រុសបង្កើតរបស់ខ្លួនក្នុងចំណោមបងប្រុសរបស់នាងទាំងបីនាក់ ហើយប្តីរបស់នាង ក៏ត្រូវជាមិត្តជិតស្និទ្ធរបស់Paulផងដែរ។

Tinaបានប្រាប់អ្នកស៊ើបអង្កេតថា Paul ធ្លាប់មានឈ្មោះ ក្នុងការស៊ើបអង្កេត
ក្នុងករណីដែលរូបគេបានបំពាននារីម្នាក់កាលពីខែធ្នូ ឆ្នាំ ១៩៨៧
ប៉ុន្តែគេមិនដែលត្រូវបានយកមកសួរចម្លើយឡើយនោះទេ។ គេក៏ធ្លាប់និយាយជាញឹកញាប់មកហើយដែរ
អំពីទំនាក់ទំនងរបស់គេជាមួយ Tina ទៅកាន់មិត្តជិតស្និទ្ធគេទៀតផង។

ក៏ប៉ុន្តែក្រោយមក នៅថ្ងៃទី ២០ ខែវិច្ឆិកាឆ្នាំ ១៩៩០ ប៉ូលីសបានសម្ភាស Paul រយៈពេល ៣៥ នាទី។
Paul ក៏បានស្ម័គ្រចិត្តផ្តល់សំណាកដើម្បីធ្វើកោសល្យវិច្ច័យ។

នៅពេលអ្នកស៊ើបអង្កេតសួរ Paul ថាហេតុអ្វីបានជាគេគិតថាគេត្រូវបានប៉ូលិស
ស៊ើបអង្កេតពីបទចាប់រំលោភ គេបានឆ្លើយយករួចខ្លួន ថា ប្រហែលជាសំណាករបស់គេ
ស្រដៀងគ្នាជាមួយនឹងមុខជនសង្ស័យហើយ។

តាមរបាយការណ៍អ្នកស៊ើបអង្កេតបានរកឃើញ ថាការនិយាយរបស់Paul គឺមានភាពជឿជាក់ជាងអ្វី
ដែលTinaបាននិយាយទៅកាន់ប៉ូលិស។ ដូច្នេះPaulក៏ត្រូវបានដោះលែងនៅថ្ងៃបន្ទាប់។

សំណួរសួរថា តើមានរឿងអ្វីកើតឡើង បន្ទាប់ពីPaulត្រូវបានដោះលែង ?

បន្ទាប់ពីPaulត្រូវបានដោះលែង ពេលគឺ នៅឆ្នាំបន្តបន្ទាប់Paul បានបំពាននារីៗដទៃ
កាន់តែសាហាវជាងមុនថែមទៀត។ ក្រៅតែពីការបំពាន គេថែមទាំងចតជារឺដេអូ
និងសម្លាប់ជនរងគ្រោះទៀតផង។

នៅពេលដែលឆ្នាំ ១៩៩០ Paul បានសម្លឹងមើលឃើញប្អូនស្រីប្រពន្ធរបស់គេ ដែលមានឈ្មោះថា Tammy Homolka មានអាយុ ១៥ ឆ្នាំ ។
គេបានតែងតែលួចមើលសកម្មភាពនាង ពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីរៀបចំគំរោងចាប់បំពាននាង ដោយប្រពន្ធរបស់គេហ៊ានជានាថា ប្អូនស្រីខ្លួននៅក្រមុំព្រហ្មចារីទៀតផង។

ការប៉ុនប៉ងរបស់Paulលើកដំបូង គឺនៅក្នុងដំណើរកម្សាន្ត នាដូវក្ដៅថ្ងៃទី ២៤ ខែកក្កដា ដោយគ្រានោះ ប្រពន្ធរបស់Paulគឺ Karla បានយកថ្នាំសណ្ដំម៉្យាង ដែលនាងលួចបានពីកន្លែងធ្វើការរបស់នាង ទៅលួចដាក់ក្នុងអាហាររបស់Tammy។ ក៏ប៉ុន្តែសំណាងល្អ Tammyបានភ្ញាក់ដឹងខ្លួន មុនពេលដែលPaulរៀបនឹងបំពានទៅលើនាង។

នៅថ្ងៃទី ២៣ ខែធ្នូ ការប៉ុនប៉ងលើកទី ២ ក៏បានកើតឡើង ក្រោយពីទទួលទានអាហារពេលល្ងាច នៅថ្ងៃបុណ្យណូអែលនៅផ្ទះគ្រួសារ Karla រួច។ Karla បានរៀបរាប់ថា ថ្ងៃនេះជាការជូនព្រហ្មចារីរបស់ប្អូនស្រីនាងទៅកាន់Paulប្ដីសណព្វចិត្តនាង ទុកជាកាដូសម្រាប់ថ្ងៃបុណ្យណូអែល។

Paul និង Karla បានលួចដាក់ថ្នាំងងុយដេក នៅក្នុងស្រាក្រឡុករបស់Tammy។ នៅពេលដែលTammyបាត់បង់ស្មារតី
Paul និងKarla បានបំពាននាង ដោយយកក្រណាត់ដែលប្រលាក់ទៅដោយថ្នាំស្ពឹកម៉្យាង ទៅខ្ទប់លើច្រមុះ និងមាត់របស់ប្អូនស្រីនាង ស្រពពេលដែល ពុកម្ដាយរបស់Tammy កំពុងតែសំរានលក់នៅជាន់ខាងលើ។

គ្រានោះ Tammyក៏ចាប់ផ្ដើមក្អួត និងបាត់បង់ស្មារតី ហើយពួកគេ
ក៏ព្យាយាមធ្វើចលនាដើម្បីឱ្យនាងដឹងខ្លួនឡើងវិញ និងបានប្រមូលភស្តុតាងទាំងប៉ុន្មាន យកទៅលាក់
ហើយនិងស្លៀកពាក់ខោអាវអោយ Tammyហើយនាំនាងចូលបន្ទប់គេងរបស់នាងវិញ។
រួចហើយធ្វើពុតជាខលទៅលេខសង្គ្រោះបន្ទាន់ ៩១១។ ប៉ុន្តែជាក្ដីសោកសង្វេក
ពីរបីម៉ោងក្រោយមកTammyត្រូវបានប្រកាសថាស្លាប់នៅមន្ទីរពេទ្យ Catherine General Hospital។

នៅយប់កើតហេតុនោះ Paul និង Karla បានធ្វើពុតជាបោកខោអាវ។
ហើយចំណែកឯសាកសពរបស់Tammy មានស្នាមរលាកដោយសារជាតុគីមីម្យ៉ាង។ តែយ៉ាងណា
មូលហេតុផ្លូវការនៃការស្លាប់របស់ Tammy គឺដោយចៃដន្យ មានន័យថាគេស្លាប់ដោយសារក្អួតចង្អោរ
ក្រោយពីផឹកស្រាហួសប្រមាណទៅវិញ។

តែយ៉ាងណាក៏ដោយ ឳពុកម្ដាយរបស់គេ ក៏មានការសង្ស័យទៅលើ Paul និង Karla ដែរ ប៉ុន្តែការសង្ស័យ
គ្រាន់តែជាការសង្ស័យប៉ុណ្ណោះ ដោយពួកគេគ្មានភស្តុតាងឡើយ។

ជនរងគ្រោះ បន្ទាប់គឺ មានឈ្មោះថា Jane Doe អាយុ១៥ឆ្នាំ ។

នៅយប់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩១ Paul បានអញ្ជើញ នាងមកញ៉ាំអាហារពេលល្ងាច
ជាមួយគេនិងប្រពន្ធរបស់គេ។

ដោយវិធីដដែល! Karla លួចដាក់ថ្នាំសណ្ដំ ចូលទៅក្នុងស្រារបស់ Jane។ នៅពេលដែល
Janeបានបាត់បង់ស្មារតីភ្លាម Karla បានប្រាប់Paulថា កាដូត្រៀម Suprise ថ្ងៃខួបកំណើតរបស់Paul
រួចរាល់ហើយ។

ដោយមិនចាំយូរPaul បានថតវីដេអូពីសកម្មដែលគេនិងប្រពន្ធរបស់គេបំពានទៅលើJane។

លុះព្រឹកឡើង Janeមិនបានដឹងខ្លួនថា ត្រូវបានប្តីប្រពន្ធទាំងពីរនេះបំពាននោះទេ Janeក៏ត្រឡប់ទៅផ្ទះធម្មតា។

បន្ទាប់មក នៅខែសីហា Janeក៏ត្រូវបានPaul និង Karla អញ្ជើញអោយមកផ្ទះគេម្តងទៀត រួចក៏ត្រូវបានពួកគេទាំងពីរដាក់ថ្នាំ និងបំពានម្តងទៀត រហូតដាច់ខ្យល់ស្លាប់តែម្តង។

ជនរងគ្រោះទី៣ គឺមានឈ្មោះថា Leslie Mahaffy ដែលមានអាយុទើបតែ១៤ឆ្នាំប៉ុណ្ណោះ។ ករណីនេះគឺដូចគ្នាទៅនឹងករណីរបស់Jane ដែរ ក៏ប៉ុន្តែ Leslie ត្រូវបានPaul ចាប់នាង និងបង្ខំនាងចូលឡាន រួចក៏ដឹកនាងទៅផ្ទះរបស់គេ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩១ គឺរលងបានតែ៨ថ្ងៃប៉ុណ្ណោះ បើគិតពីករណីរបស់Jane។

នៅពេលទៅដល់ផ្ទះរបស់គេ Paul និង Karla ក៏បានថតវីដេអូចាប់បំពានLeslie ខណៈដៃទាំងពីររបស់នាងទៅបានចងជាប់។ បើទោះជាLeslie ស្រែកអង្វរកយ៉ាងណាក៏ដោយ ក៏ពួកគេមិនព្រមដោះលែងនាងដែរ។

ក្រោយពីពួកគេទាំងពីរបានប្រព្រិត្តអំពើព្រៃផ្សៃទៅលើ Leslieរួច ពួកគេក៏យកថ្នាំម្យ៉ាង បង្ខំអោយនាងផឹកទាល់តែស្លាប់ រួចហើយក៏យកសាកសពនាង ទៅដាក់ក្នុងបន្ទប់ក្រោមដី។ ប៉ុន្តែដោយសារពួកគេខ្លាចគ្រួសារគេដឹង ពេលដែលមកញ៉ាំបាយផ្ទះគេ ពួកគេក៏សម្រេចចិត្តយកសាកសព Leslie កាត់ជាបំណែក រួចយកស៊ីម៉ង់មកបិត កុំអោយធុំក្លិន និងយកទៅបោះចោលនៅទន្លេ។

ប៉ុន្តែមានបំណែកស៊ីម៉ងមួយទម្ងន់ស្រាលបានអណ្តែតមកមាត់ច្រាំងដែលមានចម្ងាយពីផ្ទះពួកគេប្រហែល ១៨គ.ម។ ស៊ីម៉ងនេះក៏ត្រូវបានអ្នកជិតនោះប្រទះឃើញ រួមជាមួយនឹងធ្មេញរបស់Leslie ដែរ។

ប៉ុន្មានថ្ងៃក្រោយមក ពួកគេទាំងពីរ ក៏ត្រូវបានប៉ុលិសចាប់ខ្លួន រួចក៏ត្រូវបានដោះលែងវិញ ព្រោះមិនមានភស្តុតាងណា អាចស្រាយបញ្ជាក់ថា គេជាឃាតកនោះទេ។

ជនរងគ្រោះចុងក្រោយ គឺមានឈ្មោះថា Kristen French ពោលគឺ នៅថ្ងៃទី ១៦ ខែមេសាឆ្នាំ ១៩៩២ Paul និង Karla បានចាប់ចំរិត Kristen អាយុ ១៥ ឆ្នាំ នៅពេលនាង ចេញពីសាលាអនុវិទ្យាល័យកាតូលិក Holy Cross ដោយបន្សល់ទុកសាក្សីមួយចំនួន នៅទីនោះ។

ពួកគេបានចាប់បំពាន និងធ្វើទារុណកម្មនាង អស់រយៈពេលបីថ្ងៃ មុនពេលដែលពួកគេសម្រេចចិត្ត រឹតកនាងដោយខ្សែភ្លើង។

ក្នុងកំឡុងពេលជាប់ឃុំឃាំង Kristen មិនអាចបិទភ្នែកគេងលក់ឡើយ ហើយត្រូវបានពួកគេបង្ខំឱ្យផឹកស្រាស្រវឹងយ៉ាងខ្លាំង និងបង្ខំអោយនាង មើលវីដេអូដែលពួកគេបំពានទៅលើLeslieទៀតផង។

ភ្លាមៗនោះ Kristen ខឹងរួចក៏ហៅPaulថាជាមនុស្សកំសាក រួចនិយាយថា “ខ្ញុំមិនដឹងថាប្រពន្ធរបស់អ្នក អាចឈរនៅក្បែរអ្នកដោយរបៀបណាទេ” ។ ដោយសារតែបែបនេះ នាងក៏ត្រូវពួកគេវាយ និងធ្វើបាបយ៉ាងខ្លាំងមុនពេលនាងស្លាប់។

ជាថ្មីម្តងទៀត ប្តីប្រពន្ធមួយគូរនេះ បានទុកសាកសពនៅក្នុងផ្ទះរបស់ពួកគេ។ ក្រោយមក ពួកគេបានសម្អាតសាកសពKristen ហើយកាត់សក់របស់នាង មុនពេលពួកគេបោះចោលសាកសពនេះ ចូលទៅក្នុងប្រឡាយមួយ នៅBurlingtonជិតទីបញ្ចុះសពរបស់Leslie។
ក្រោយមកទៀត Paul ក៏ត្រូវបានប៉ូលីសពីរនាក់សម្ភាស បន្ទាប់ពីឃាតកម្មរបស់Kristenរំលងបានមួយខែ ប៉ុន្តែប៉ូលិស បានចាត់ទុកថា គេមិនទំនងជាជនសង្ស័យពិតប្រាកដនោះទេ បើទោះបីជាគេ បានសារភាពថា គេធ្លាប់ត្រូវបានសម្ភាសកាលពីមុនរួចមកហើយ ដោយទាក់ទងនឹងករណីមុនៗ ក៏ដោយ។

ដូចដែលពាក្យគេនិយាយថា ឈាមស្រែកស្បែកហៅពិតមែន ពោលគឺ នៅថ្ងៃទី ២៧ ខែធ្នូ Paul បានយកពិលមកវាយKarlaយ៉ាងខ្លាំង
ដោយបន្សល់ទុកស្នាមជាំនៅលើឆ្អឹងជំនីនិងភ្នែកទាំងពីររបស់នាង។

ទោះយ៉ាងណាក៏ដោយ នៅថ្ងៃទី ៤ ខែមករាឆ្នាំ ១៩៩៣ នាងនៅតែបន្តធ្វើការដដែរ ហើយនៅពេលដែលមានអ្នកសួរអំពីស្នាមជាំរបស់នាង នាងព្យាយាមប្រាប់មិត្តរួមការងាររបស់នាងថា នាងជួបគ្រោះថ្នាក់ចរាចរណ៍។

មិត្តរួមការងាររបស់នាង មិនជឿនាងទេ ហើយបានជូនដំណឹងនេះ ដល់ពុកម្តាយនាងរបស់នាង ទើបឪពុកម្តាយនាង នាំនាងទៅព្យាបាលនៅមន្ទីរពេទ្យ។

នៅពេលដែលទៅដល់ទីនោះ Karlaបានអះអាងថា នេះគឺជាជម្លោះរវាងប្តីប្រពន្ធតែប៉ុណ្ណោះ ហើយក៏បានដាក់ការចោទប្រកាន់ប្រឆាំងទៅនឹងPaulពីការប្រើប្រាស់អំពើហិង្សាទៅលើរូបគេ ហើយ Paulក៏ត្រូវបានចាប់ខ្លួន។

ចែដន្យអី ស្រាប់តែសំណាក ដែលPaul ធ្លាប់បានផ្តល់ឱ្យ កាលពីពីរឆ្នាំមុន ត្រូវបានគេធ្វើតេស្តម្តងទៀត ដោយនៅពេលនេះ បានបង្ហាញថា អត្តសញ្ញាណគេស្របទៅនឹង សំណាករបស់អ្នកចាប់បំពាននារីប្រចាំទីក្រុង Scarborough កាលពីឆ្នាំនោះឯង។

ក្រោយមក Karla បានផ្លាស់ទៅទីក្រុង Brampton ជាមួយមីង និងពូរបស់នាង ហើយក៏បានសារភាព ប្រាប់សាច់ញាតិរបស់នាងថា Paulគឺពិតជាឃាតកបំពានដែលប៉ូលីសរកមុខ និងជាឃាតកស្លាប់LeslieនិងKristen ផងដែរ។

នៅក្នុងខែកុម្ភៈ នាងក៏បានស្វែងរកអភ័យឯកសិទ្ធិពេញលេញ ដើម្បីរួចខ្លួនពីកាកាត់ទោស ដែលជាថ្នូរដោះដូរ រវាងកិច្ចសហប្រតិបត្តិការរបស់នាងជាមួយប៉ូលិស ប៉ុន្តែត្រូវបានបដិសេធ។

ផ្ទុយទៅវិញ នាងត្រូវបានតុលាការ ផ្តល់ការសម្រេចចិត្តរយៈពេលមួយសប្តាហ៍ ដើម្បីទទួលយកការជាប់ពន្ធនាគាររយៈពេល ១២ ឆ្នាំ ពីការចោទប្រកាន់ពីបទឃាតកម្មចំនួន ៣ ករណី ក៏ដូចជាឧក្រិដ្ឋកម្មផ្សេងទៀតផងដែរ។

ដោយគ្មានជម្រើសKarla បានយល់ព្រមផ្តល់សក្ខីកម្មប្រឆាំងនឹង  Paul នៅក្នុងការជំនុំជម្រះរបស់គេ ដែលបានកើតឡើងនៅឆ្នាំ ១៩៩៥។

ទីបំផុត នៅថ្ងៃទី ១ ខែកញ្ញា Paul ត្រូវបានកាត់ទោស ឱ្យជាប់ពន្ធនាគារអស់មួយជីវិត ដោយគ្មានការដោះលែងយ៉ាងហោចណាស់ ម្ភៃប្រាំឆ្នាំទើបមានសិទ្ធស្នើរដោះលែង។

គេត្រូវបានគេដាក់នៅឱ្យដាច់ដោយឡែក ពីអ្នកទោសផ្សេងទៀត ដោយសារតែគេជាប់ឈ្មោះជា“ពិរុទ្ធជនដែលមានគ្រោះថ្នាក់” ហើយគេត្រូវបានគេចាត់ទុកថា គេនឹងមិនមានឱកាសត្រូវបានគេដោះលែងឡើយ។ គួរបញ្ជាក់ផងដែរថា វីដេអូដែលពួកគេថតទុកទាំងប៉ុន្មាន ត្រូវបានបំផ្លាញដោយអាជ្ញាធរប្រទេសកាណាដា ព្រោះជៀសវាងការបែកធ្លាយ ទៅកាន់សារធារណៈជននោះទេ។

តាមរយៈរឿងរ៉ាវនេះ យើងអាចស្វែងយល់បានថា ទង្វើរបស់ឪពុកម្តាយ អាចជះឥទ្ធិពលដល់កូនៗ បើសិនជាមិនមានការទទួលបានការណែនាំផ្លូវដ៏ត្រឹមត្រូវដល់ពួកគេ។ មនុស្ស គឺមិនអាចវាសតម្លៃបាន តាមរយៈរូបរាងខាងក្រៅឡើយ ព្រោះថា មនុស្សអាក្រក់ ឬល្អ គឺមិនអាស្រ័យទៅលើ មុខរបរ និងសម្រស់នោះឡើយ។ ក្នុងសង្គមមួយ គឺតែងតែមានមនុស្សល្អ និងអាក្រក់ ដែលមិនបានបែងចែកភេទឡើយ ដូចនេះ មិនថាទៅណាមកណា គឺចាំបាច់ណាស់ ត្រូវមានស្មារតីល្អ និងប្រុងប្រយ័ត្នជានិច្ច។ ទោះជាយ៉ាងណាក៏ដោយ ព្រៃរឿងសង្ឃឹមថា រឿងរ៉ាវបែបនេះ គឺនឹងមិនកើតឡើងនៅក្នុងសង្គមយើងឡើយ។ សូមស្តាប់ដោយការត្រិះរិះពិចារណា។ យើងនឹងជួបគ្នាម្តងទៀត ក្នុង CamID Podcast ក្រោយ។ សម្រាប់ពេលនេះ សុបិនល្អ និងរាត្រីសួស្តី។

Links and Resources

https://criminalminds.fandom.com/wiki/Paul_Bernardo_and_Karla_Homolka
https://murderpedia.org/male.B/b/bernardo-paul.htm
https://www.ctvnews.ca/canada/teen-killer-and-serial-rapist-paul-bernardo-again-denied-parole-1.5480350
https://torontosun.com/news/local-news/hunter-parole-board-documents-reveal-a-delusional-paul-bernardo